#### រឿង

# សារិកាស្អប់អ្នកកុហក



# រឿង សារិកាស្អប់អ្នកកុហក

និពន្ធដោយ អ្នកស្រី កែវ ណារុំ
គូររូបដោយ លោក គឹម សុគន្ធ

រក្សាសិទ្ធិដោយ អង្គការសន្តិស្នេហ៍ក្រចិត្ត(SVA)

បោះពុម្ពឆ្នាំ២០០៩

# រឿង សារិកាស្អប់អ្នកកុហក



និពន្ធដោយ កែវ ណារុំ
វិចិត្រូបភាពដោយ គីម សុគន្ធ
បោះពុម្ពផ្សាយដោយអង្គការសន្តិស្វ័គ្រចិត្ត

ផ្ទះសៅមានសារិកាមួយចេះនិយាយឆ្លើយឆ្លងជាមួយមនុស្ស ។ រាល់ពេលជួបសារិកា សៅតែងនិយាយថា"អាវងអ្វើយ!"។ ឯសារិកាតែងតែឆ្លើយតបវិញថា "បាទ!" ។





ថ្ងៃមួយ  សៅហៅសារិកាដូចពេលមុន "អាវែងអ្អើយ!"  តែសារិកាមិនឆ្លើយតប ហើយសំកុកឱនមុខជ្រប់សម្លឹងដី ។







សៅគិតថាសារិកាឈឺ ក៏រត់ទៅជំរាបម្ដាយ ដើម្បីឱ្យគាត់ហៅពេទ្យសត្វ
មកមើលសារិកា ។



ម្ដាយសៅក៏ដើរចូលទៅក្នុងបន្ទប់ដើម្បីយកទូរស័ព្ទមកនិយាយ តែរកមិនឃើញ ។ គាត់ចេញពីបន្ទប់វិញ ហើយសម្លឹងមុខសៅដូចជាចង់សួររកទូរស័ព្ទ ។ ពេលនោះ សៅនិយាយរដាក់រដុបថា "ខ្ញុំអត់ដឹងទេ!" ។







ម្តាយក៏ពោលថា "បើមិនមែនកូន តើអ្នកណាមកយកទូរស័ព្ទម៉ែ?"។ ពេលនោះសារិកាក៏ងើបមុខឡើង រួចនិយាយថា "ខ្ញុំបានឃើញ ..." ។



ឮដូចនោះ សៅស្ទុះទៅជិតសារិកាមួយរំពេច ហើយនិយាយគំរាមតិចៗថា "ឯងចង់ឈឺឬ?" សារិកាភ័យណាស់ ក៏ទទះស្លាបហើរទៅទំលើស្មាម្ដាយសៅ ។





ម្ដាយសៅលួងលោមថា"អាវង ឯងនិយាយការពិតប្រាប់ម៉ែមក កុំខ្លាច!" សារិកាក៏និយាយបន្តថា "ខ្ញុំឃើញបងសៅយកទូរស័ព្ទចេញពីកាបូបម៉ែ ហើយចេញទៅខាងក្រោយផ្ទះ" ។





ម្តាយក៏សួរបញ្ជាក់ថា"កូនសៅ! តើពិតដូចពាក្យអាវងនិយាយដែរឬទេ?"។ សៅជំរាបម្តាយតាមត្រង់ ព្រមទាំងលុតជង្គង់ពីមុខម្តាយ ហើយទាញយកទូរស័ព្ទមកបង្ហាញ "កូនសូមអភ័យទោសម៉ែ! កូនបានយកទូរស័ព្ទម៉ែមែននេះនែ!" ។





ម្តាយទទួលទូរស័ព្ទហើយ និយាយថា"កូនមិនត្រូវយករបស់អ្វី ដោយលាក់លៀមឡើយ ម្យ៉ាងទៀតកូននៅក្មេងណាស់កូនមិនត្រូវប្រើទូរស័ព្ទទេ"។ ពេលនោះ អាវងក៏និយាយបន្តរថា "មែនហើយៗខ្ញុំស្អប់អ្នកកុហកណាស់"។







សៅក៏និយាយទៅកាន់អាវងថា "ខ្ញុំសន្យាថា ឈប់យករបស់អ្វីដោយមិនបានជំរាបម៉ែឡើយ!"។ ឯសារិកាបែរជាសួរទៅម្ដាយថា "អ្នកម៉ែ! បងសៅឈប់ធ្វើចោរហើយឬ?" ម្ដាយនិយាយថា "បងឯងមិនមែនចោរទេ!" ។





អាវងសប្បាយចិត្តណាស់ ក៏ទទះស្លាបភិបៗហើរភិលទៅទំលើស្នាសៅ រួចហើយ ម្តងវាទំលើមែកស្វាយ ម្តងវាទំលើមែកចំប៉ា ម្តងវាទំលើមែកឃីហ៊ុបដោយស្រែកច្រៀងថា "អែយ៉ាៗអែយ៉ាៗ! បងសៅអស្ចារ្យ មិនមែនចោរទេ បងសៅសន្យាឈប់ធ្វើខុសហើយ" ។





សៅក៏ទះដៃ ឡើងរាំតាមចំរៀងសារិកា ហើយបន្ទរថា "មែនហើយៗ ខ្ញុំគ្រាន់តែឆ្លោយមួយដងប៉ុណ្ណោះ ខ្ញុំមិនមែនចោរទេ! ខ្ញុំជាកូនល្អរបស់ម៉ែ" ។/

—ចប់—





№ 950576

អង្គការសន្តិស្ម័គ្រចិត្ត
Shanti Volunteer Association